ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ អង្គារ ១២ កើត ខែ ភទ្របទ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៩*

**សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មាន**
**ស្តីពីជំនួបរវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ជាមួយលោក Yasuhisa Ojima ប្រធានស្ថានតំណាងថ្មីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំកម្ពុជា**

នាព្រឹកថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសមជាមួយលោក Yasuhisa Ojima ប្រធានស្ថានដំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំកម្ពុជា ដែលទើបត្រូវបានតែងតាំងជាប្រធានស្ថានតំណាងថ្មីនៅកម្ពុជា ដើម្បីពិភាក្សាអំពីគោលនយោបាយសារពើពន្ធ (Fiscal Policy) ដែលរួមមាន ការប៉ាន់ស្មានតម្រូវការហិរញ្ញប្បទានក្នុងការគាំទ្រគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា, កម្មវិធីកែទម្រង់អភិបាលកិច្ចសារពើពន្ធ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពមន្ត្រីជំនាញកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលជានិច្ចកាលតែងតែពង្រឹងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ចូលរួមយ៉ាងសកម្មដល់ការអភិវឌ្ឍកម្ពុជា ។ ទន្ទឹមនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានជម្រាបជូនលោក Yasuhisa Ojima អំពីតម្រូវការ និងការពង្រឹងសមត្ថភាពមន្ត្រីជំនាញសម្រាប់កម្ពុជា ដែលអាចវាយតម្លៃអំពីផលប៉ះពាល់នៃបញ្ហាប្រឈម និងហានិភ័យទាំងខាងក្នុងនិងក្រៅ មកលើស្ថានភាពសេដ្ឋកិច្ច, ទំហំពាណិជ្ជកម្ម, វិស័យហិរញ្ញវត្ថុ និងកិច្ចអភិវឌ្ឍសង្គម ក្នុងគោលដៅដើម្បីដាក់ចេញនូវវិធានការគោលនយោបាយជាយុទ្ធសាស្ត្រ និងជាកញ្ចប់សម្រាប់រយៈពេលខ្លី, មធ្យម និងវែងដោយបុរេសកម្ម, ទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏ចង្អុលបង្ហាញអំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពមន្ត្រីជំនាញកម្ពុជា ដោយគួរផ្តោតលើ ៣ កម្រិត÷ ១. ការងារដែលមានចរិតជាយុទ្ធសាស្ត្រសម្រាប់ការដឹកនាំសម្របសម្រួល ជាអាទិ៍ ការដឹកនាំសម្របសម្រួលការកែទម្រង់ប្រព័ន្ធថវិកា, យុទ្ធសាស្ត្រគៀរគរចំណូល, យុទ្ធសាស្ត្រនៃការកែទម្រង់លទ្ធកម្ម សាធារណៈ ។ល។

២. បំពាក់ជំនាញបច្ចេកទេសការងារ (Skill developments) បន្ថែមទៀត ចំពោះការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដូចជា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ និងយន្តការតាមដាន និងវាយតម្លៃ ។ល។ ៣. កម្មវិធីបណ្តុះបណ្តាលពិសេសដាច់ដោយឡែកសម្រាប់បង្កើនសមត្ថភាពជំនាញ ដែលអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ឬដោះស្រាយបញ្ហាជាក់ស្តែងណាមួយដែលកើតមានឡើងក្នុងពេលអនុវត្តន៍កម្មវិធី ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានគូសបញ្ជាក់ថា ចំពោះការប៉ាន់ស្មានតម្រូវការហិរញ្ញប្បទានសម្រាប់ក្របខ័ណ្ឌ និងយុទ្ធសាស្ត្រនៃការគាំទ្រគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals) គួរផ្សារភ្ជាប់ និងមានសង្គតភាពជាមួយនឹងក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍របស់កម្ពុជា និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុកម្ពុជា តែម្តង ។

លោក **Yasuhisa Ojima** បានសម្តែងនូវសេចក្តីសោមនស្សរីករាយ ដែលបានមកបំពេញបេសកកម្មនៅកម្ពុជា និងបានបញ្ជាក់ថា នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការល្អ, បន្តរួមចំណែករក្សានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, លើកកម្ពស់សមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញរបស់កម្ពុជា តាមរយៈការចែករំលែកពុទ្ធិ ទាំងចំណេះដឹង និងចំណេះធ្វើ ក្នុងការវាយតម្លៃហានិភ័យក្នុង និងក្រៅ សម្រាប់រៀបចំគោលនយោបាយសេដ្ឋកិច្ច, សារពើពន្ធ និងបណ្តាវិធានការជាយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ក៏បានជូនពរលោក Yasuhisa Ojima និងសហការី ទទួលបានជោគជ័យ នាពេលបំពេញអាណត្តិបេសកកម្មនៅកម្ពុជា ។